**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៧៧៩ ព.ណ.ន.ព.

ថ្ងៃអង្គារ ៧កើត ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៩

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ផលិតករ ឬអ្នកនាំចេញទាំងអស់ឲ្យបានជ្រាបថា យោងប្រកាស អន្តរក្រសួងលេខ ១៦២៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម និងយោងបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប ព្រះរាជាណាចក្រកម្ពុជាបានចូលរួមអនុវត្តការចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter System-REX) របស់សហភាពអឺរ៉ុបសម្រាប់ការនាំចេញទំនិញគ្រប់ប្រភេទពីព្រះរាជាណាចក្រកម្ពុជាទៅកាន់សហភាពអឺរ៉ុបស្ថិតក្រោមគម្រោង"ការអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងគ្រឿងសព្វាវុធ (EBA)" និងប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់ប្រទេសណ័រវែស ស្វីស និងទួរគី ដើម្បីមាននីតិសម្បទាក្នុងការប្រកាសប្រភពដើម (Statement On Origin) ជំនួសឲ្យការប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។ ក្រសួងពាណិជ្ជកម្មសង្កេត ឃើញថាក្នុងរយៈពេលចាប់តាំងពីមាន សេចក្តីជូនដំណឹងចំនួន០៣លើក រហូតមកដល់បច្ចុប្បន្ន គឺនៅមានក្រុមហ៊ុននាំចេញទៅសហភាពអឺរ៉ុប ណ័រវែស ស្វីស និងទួរគី មួយចំនួនធំមិនទាន់បានមកស្នើសុំចុះឈ្មោះតាមការជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្មនៅឡើយទេ។

ដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ពីការទទួលបាននូវភាពអនុគ្រោះពន្ធ សម្រាប់ការនាំចេញទំនិញពីព្រះរាជាណាចក្រកម្ពុជាទៅកាន់ ទីផ្សារសហភាពអឺរ៉ុប និងប្រព័ន្ធអនុគ្រោះរបស់ប្រទេសណ័រវែស ស្វីស និងទួរគី ផលិតករ ឬ អ្នកនាំចេញទាំងឡាយណា ដែលមិនទាន់បានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter System-REX) សូមប្រញាប់មកចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញសម្រាប់ប្រកាសដើមកំណើតទំនិញ (Statement On Origin) ជំនួសឲ្យការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ ។

ជាមួយគ្នានេះដែរ ដើម្បីសម្រួលនីតិវិធីដល់អ្នកនាំចេញដែលមកធ្វើការចុះបញ្ជីនៅក្នុងប្រព័ន្ធ REX សម្រាប់អ្នកគ្រប់គ្រងក្នុងក្រុមហ៊ុន (មិនមែនជាតំណាងអ្នករត់កម្រៃជើងសារ និងតំណាងដែលមិនមានចំណែកក្នុងការទទួលខុសត្រូវក្នុងក្រុមហ៊ុន) ដែលបានទទួលសិទ្ធតាមផ្លូវច្បាប់ពីម្ចាស់ភាគហ៊ុនដែលមានឈ្មោះក្នុងលក្ខន្តិកៈក្រុមហ៊ុន គឺមានសិទ្ធក្នុងការចុះហត្ថលេខាលើលិខិតស្នើសុំ និងកែសម្រួលការចុះបញ្ជី REX ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង៖

១-ឯកឧត្តម ហូ ស៊ីវយ៉ុង ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ: ០១២ ៨៣៨ ៩០៩ សារអេឡិកត្រូនិក: hosivyong@yahoo.com

២-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៩៤៨ ៤៨៤ សារអេឡិកត្រូនិក: batithsy@yahoo.com

៣-លោកស្រី កែ បូណា ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៩៦៩ ៦៧៦ សារអេឡិកត្រូនិក: ke_bona@yahoo.com
ឬសារអេឡិកត្រូនិក: exportimportdept@moc.gov.kh

អាស្រ័យហេតុនេះ សូមផលិតករ ឬអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ក្រសួងពាណិជ្ជកម្ម

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469